ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ:.....០០៤.....ស.ក.ណ

# សេចក្តីកំណត់
## ស្តីពីការកំណត់ថ្លៃសិទ្ធជាវទឹក

## អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

-បានឃើញព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧-០៦-៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ។
-បានឃើញអនុក្រឹត្យ លេខ ៥២ នអក្រ.បក ចុះថ្ងៃទី១៩-១២-៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។
-បានឃើញអនុក្រឹត្យ លេខ ៣២ នអក្រ. ចុះថ្ងៃទី៣១-១២-៨៧ ស្តីពីការផ្គត់ផ្គង់និងប្រើប្រាស់ទឹកស្អាត ។
-បានឃើញអនុក្រឹត្យ លេខ ៣៤ នអក្រ.បកចុះថ្ងៃទី១២-៦-០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២អនក្រ.បក។
-បានឃើញអនុក្រឹត្យ លេខ ១៤ នអក្រ.បកចុះថ្ងៃទី ២៤-០៥-០៤ ស្តីពីការផ្ទេរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអោយស្ថិតនៅក្រោមអាណាព្យាបាល នៃក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល។
-បានឃើញអនុក្រឹត្យ លេខ ៦៦៤ នអក្រ.បក ចុះថ្ងៃទី០៨-០៦-១២ ស្តីពីការតែងតាំងអគ្គនាយក រ.ទ.ស.ភ។
-បានឃើញលក្ខន្តិកៈបុគ្គលិក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានកែសម្រួលលើកទី ៣និងអនុម័តដោយក្រុមប្រឹក្សា ភិបាល អណត្តិទី ៤ នាសម័យប្រជុំលើកទី ១៧ ថ្ងៃទី ២៦-០៦-២០១២ ។
-បានពិនិត្យឃើញថា តម្លៃនាឡិកាទឹកនិងសម្ភារមួយចំនួន មានតម្លៃកើនឡើង ។

## <u>កំណត់</u>

**ប្រការ១** : -អតិថិជនដែលត្រូវតបណ្តាញទឹកចូលផ្ទះ ត្រូវបង់ថ្លៃសិទ្ធជាវទឹក ។ ការតបណ្តាញទឹកជាបន្ទុករបស់រដ្ឋាករទឹកស្វយត័ក្រុងភ្នំពេញ ។
-រាល់អតិថិជនរបស់រដ្ឋាករទឹកស្វយត័ក្រុងភ្នំពេញ ត្រូវបង់ប្រាក់តក់ថ្លៃប្រើប្រាស់ទឹក ដូចមានចែងក្នុងអនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៨៧ ស្តីពីការផ្គត់ផ្គង់និងប្រើប្រាស់ទឹក ។
-រាល់បណ្តាញចូលផ្ទះ ចាប់ពីបំពង់មេសាធារណៈរហូតដល់នាឡិកាទឹក ជាបន្ទុករបស់រដ្ឋាករទឹកស្វយត័ក្រុងភ្នំពេញ ។
-ថ្លៃសិទ្ធជាវទឹកសម្រាប់បណ្តាញថ្មីទំហំនាឡិកា ១៥មម ដល់ ៤០មម ត្រូវគិតដូចតារាងខាងក្រោម (ជា រៀល) ៖

| លរ. | ប្រវែងបណ្តាញ | ទំហំនាឡិកា | | | |
|---|---|---|---|---|---|
| | | ១៥ មម | ២០ មម | ២៥ មម | ៤០ មម |
| ១ | ពី ០ ដល់ ១០ម | ៣៦៥.៥០០៖០០ | ៨៨៩.៧០០៖០០ | ១.០៥៦,០០០៖០០ | ២.៥៨១.០០០៖០០ |
| ២ | លើសពី ១០ ដល់ ២០ម | ៤៣៧.៥០០៖០០ | ៩៦៥.២០០៖០០ | ១.១៣១,០០០៖០០ | ២.៧៤២.០០០៖០០ |
| ៣ | លើសពី ២០ ដល់ ៣០ម | ៥២៧.០០០៖០០ | ១.០៤០.៨០០៖០០ | ១.២០៦,០០០៖០០ | ២.៩០៣.០០០៖០០ |
| ៤ | លើសពី ៣០ ដល់ ៤០ម | ៦២៤.៣០០៖០០ | ១.១១៦.៣០០៖០០ | ១.២៨២,០០០៖០០ | ៣.០៦៥.០០០៖០០ |
| ៥ | លើសពី ៤០ ដល់ ៥០ម | ៧២០.៩០០៖០០ | ១.១៩១.២០០៖០០ | ១.៣៥៧,០០០៖០០ | ៣.២២៦.០០០៖០០ |

**ប្រការ២** : រាល់ថ្លៃសិទ្ធជាវទឹកសម្រាប់បណ្តាញថ្មីខាងលើនេះ អតិថិជនជាអ្នកទទួលបន្ទុកចំណាយតាមតម្លៃកំណត់ខាងលើដោយបូកបន្ថែមពន្ធអាករលើតម្លៃបន្ថែម (VAT)១០% ។

**ប្រការ ៣** :ចំពោះការដឹកផ្តល់ដើម្បីតបណ្តាញទឹក អតិថិជនត្រូវទាក់ទងជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានី-ខេត្តនិងអាជ្ញាធរមូលដ្ឋាន ។

**ប្រការ ៤** :រាល់សេចក្តីកំណត់ទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីខ្លឹមសារខាងលើនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** :គ្រប់នាយកដ្ឋាន - ការិយាល័យ - អង្គភាព ដែលពាក់ព័ន្ធត្រូវអនុវត្តន៍សេចក្តីកំណត់នេះ អោយមានប្រសិទ្ធភាពចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ,ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤

**អគ្គនាយក**

ស៊ឹម ស៊ីថា

**កន្លែងទទួល** ;

-ដូចក្នុងប្រការ "៥"

-"ដើម្បីអនុវត្ត និងមុខការ"

-កាលប្បវត្តិ-ឯកសារ